# របាយការណ៍សកម្មភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

I. **ស្ថានភាពទូទៅ**

II. នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានមន្ត្រីសរុបចំនួន ១៩ រូប (ស្រី ០៦ រូប) ក្នុងនោះមន្ត្រីកម្មសិក្សា ចំនួន ០២ រូប (ស្រី ០១ រូប) និងមន្ត្រីកិច្ចសន្យាចំនួន ០១ រូប(ស្រី ០១ រូប) ៖

- ចំនួនមន្ត្រីរាជការ ដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ៖ គ្មាន
- ចំនួនមន្ត្រីរាជការ ដែលបានទៅបំពេញបេសកកម្មនៅក្រៅប្រទេស ៖ ០១រូប
  ចំនួនមន្ត្រីរាជការ សម្រាកលំហែមាតុភាព ៖ គ្មាន
- ចំនួនឈឺ ៖ ០១រូប
- ចំនួនមន្ត្រីកិច្ចសន្យាសុំច្បាប់ទៅក្រៅប្រទេស ០១រូប
- ចំនួនមន្ត្រីរាជការ ដែលបានសហប្រតិបត្តិការជាមួយអង្គការ និងកម្មវិធី ៖ គ្មាន

III. **លទ្ធផលការងារ**

**1. ការងារប្រជុំ និងបណ្តុះបណ្តាល**

ថ្នាក់ដឹកនាំ និងមន្ត្រី បានចូលរួមកិច្ចប្រជុំចំនួន ០៤ លើក និងសិក្ខាសាលាចំនួន ០១ លើក ៖

- **ការងារប្រជុំ**

- ប្រធាននាយកដ្ឋាន និងប្រធានការិយល័យ សរុប ០២រូប (ស្រី ០ រូប ) ចូលរួមប្រជុំស្តីពី ការបូកសរុបលទ្ធផលស្នើសុំគម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងការលើកគម្រោងស្នើសុំជំនួយក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ សាធារណរដ្ឋកូរ៉េ នៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣
- ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធានការិយល័យ សរុប ០៣រូប (ស្រី ០១ រូប ) ចូលរួមប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំពិព័ណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងរចនាសម្ព័ន្ធរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងាររៀបចំចងក្រងការពិព័ណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣
- ប្រធាននាយកដ្ឋាន និងប្រធានការិយល័យ សរុប ០២រូប (ស្រី ០ រូប ) ចូលរួមប្រជុំពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៦ និងទិសដៅឆ្នាំ ២០១៧ ក្រោមអធិតីភាព ឯកឧត្តម ហួត សារីម អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០១
- នាយកដ្ឋានធ្វើការប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ និងលើកទិសដៅខែមីនា ឆ្នាំ ២០១៧ នៅព្រឹកថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣ ។

- **សិក្ខាសាលា**

- ប្រធាននាយកដ្ឋាន និងអនុប្រធានការិយល័យ ០១ រូប (ស្រី ០ រូប ) ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និង និងចែករំលែកបទពិសោធន៍លើកទី ២ របស់គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ (Cambodia Southeast Asia Disaster Risk Management ) នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១៧ សាលប្រជុំជាន់ទី ០៣ ។

**2. កម្មវិធីផ្សេងៗ**

- អនុប្រធាននាយកដ្ឋាន ០១ រូប ចូលរួមកម្មវិធីបុណ្យមាឃបូជា នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅបរិវេណព្រះមហាសក្យមុន្នីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ) ក្រោមអធិបតីភាព **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។